# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

## សារប្រគេន និង ជូនពរ

### ប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនជនរួមឈាមខ្មែរកម្ពុជាក្រោម ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៧

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ !

សូមគោរពជនរួមឈាមជាទីស្នេហា !

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៧ ត្រូវនឹងគ.ស.២០១៣ ក្នុងនាមថ្នាក់ដឹកនាំសហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមប្រសិទ្ធពរបវរមហាប្រសើរ ប្រគេនព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជូនបងប្អូនជនរួមឈាមទាំងអស់ បានប្រកបដោយសេចក្តីសុខ សេចក្តីចម្រើន និងសុភមង្គលគ្រប់ៗក្រុមគ្រួសារ និងទទួលបាននូវសិទ្ធិសេរីភាពពេញលេញក្នុងឋានៈជាម្ចាស់នៃទឹកដីកម្ពុជាក្រោម កុំបីខាន ។ សូមទេវតាឆ្នាំចាស់ ព្រះមេត្តានាំយកទៅជាមួយនូវសេចក្តីទុក្ខសោក រោគភ័យ ភាពក្រីក្រ អំពើជិះជាន់ ការគាបសង្កត់ ការបំបិទសិទ្ធិសេរីភាព និងអពមង្គលទាំងឡាយ កុំឱ្យមាននៅសេសសល់នៅក្នុងខណ្ឌសន្តានជនរួមឈាម និងសង្គមជាតិខ្មែរកម្ពុជាក្រោមឡើយ ។

បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ !

បងប្អូនជនរួមឈាមជាទីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត !

ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងនូវការគោរព និងកោតសរសើរដោយស្មោះអស់ពីដួងចិត្តចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនរួមឈាមទាំងអស់ ដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោមដ៏អភ័ព្វរបស់យើង ទោះបីរស់នៅយ៉ាងវេទនាក្រោមនឹមត្រួតត្រាអាណានិគមវៀតណាមរាប់សិបឆ្នាំមកហើយក៏ដោយ ប៉ុន្តែស្មារតីនៃឧត្តមគតិស្នេហាជាតិ និងគោរពទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិខ្មែរនៅតែរក្សាបានយ៉ាងខ្ជាប់ខ្ជួន មិនដែលបោះបង់ចោលម្តងណាឡើយ ។ នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ជារៀងរាល់ឆ្នាំ នៅលើទឹកដីកម្ពុជាក្រោម ប្រជារាស្ត្រខ្មែរបានរៀបចំគ្រឿងសក្ការៈបូជា ដើម្បីអបអរសាទរទទួលទេវតាឆ្នាំថ្មីនៅគ្រប់លំនៅដ្ឋាន ។ នៅតាមវត្តអារាមនានា ពុទ្ធបរិស័ទនៅគ្រប់ទិសទីបានមកជួបជុំគ្នាយ៉ាងច្រើនកុះករ វេរចង្ហាន់ប្រគេនព្រះសង្ឃ ដើម្បីដារបង្សុកូលឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធបុព្វការីជន និងប្រគេនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ និងជូនវិញ្ញាណក្ខន្ធវីរបុរស ព្រមទាំងស្តាប់ព្រះសង្ឃសម្តែងព្រះធម្មវិសេសទេសនាអំពីរឿងព្រះវេស្សន្តរជាតក ឬមង្គលសូត្រចំនួនបី

យប់បីថ្ងៃជាដើម។ ម្យ៉ាងទៀត ចំពោះបងប្អូនរួមឈាមនៅឯនាយសមុទ្រឯណោះវិញ ក៏មានស្មារតីមិនខុសពីបងប្អូនរួមឈាមនៅឯមាតុភូមិកម្ពុជាក្រោមនោះដែរ ទោះបីមានភ័ព្វវាសនាបានទៅរស់នៅលើទឹកដី ដែលពោរពេញទៅដោយសេរីភាព និងសម្បូណ៌បែបយ៉ាងណាក៏ដោយ ក៏មិនដែលបោះបង់ចោលឧត្តមគតិស្នេហាជាតិមាតុភូមិរបស់ខ្លួនម្តងណាឡើយ នៅតែបន្តការតស៊ូដោយបានចូលរួមគ្រប់សកម្មភាព ដែលជាឧត្តមប្រយោជន៍ប្រជារាស្ត្រ និងមាតុភូមិកម្ពុជាក្រោមជានិច្ច ។

ឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវដល់បងប្អូនជនរួមឈាមទាំងអស់ មេត្តាក្រោកឡើងរួបរួមសាមគ្គីគ្នាជាធ្លុងមួយជុំវិញសហគមន៍ខ្មែរកម្ពុជាក្រោម ដើម្បីបន្តការតស៊ូទាមទារសិទ្ធិសេរីភាពក្នុងឋានៈយើងជាម្ចាស់ទឹកដីរហូតបានជោគជ័យជាស្ថាពរ ។

ស្របឱកាសនេះដែរ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេន និងជូនដំណឹង ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមឈាមទាំងអស់មេត្តាជ្រាបថា ទិវាកាន់ទុក្ខជាតិខ្មែរ ខួបគម្រប់ ៦៤ឆ្នាំ នៃថ្ងៃអាណានិគមបារាំងកាត់ទឹកដីកម្ពុជាក្រោមឱ្យអាណានិគមវៀតណាម និងពិធីបុណ្យរាប់បាត្រព្រះសង្ឃ ១៩៤៩អង្គ នឹងប្រព្រឹត្តទៅនៅថ្ងៃទី 0៤ ខែមិថុនា គ.ស.២០១៣ ដូចរៀងរាល់ឆ្នាំ។ ពិធីបុណ្យនេះដែលអាចប្រព្រឹត្តទៅបានតាមការគ្រោងទុកអាស្រ័យទៅលើសទ្ធាជ្រះថ្លានៃការឧបត្ថម្ភគាំទ្ររបស់បងប្អូនជនរួមឈាមទាំងស្រុង ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ សូមបួងសួងគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកព្រមទាំងទេវតាទាំងមួយម៉ឺនលោកធាតុ ជាពិសេសទេវតារក្សាឆ្នាំថ្មី ព្រះនាម***ទុង្សាទេវី*** សូមជួយបីបាច់ថែរក្សាព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងប្រជារាស្ត្រខ្មែរកម្ពុជាក្រោមគ្រប់រូប ឱ្យទទួលបាននូវសិទ្ធិសេរីភាពពេញលេញក្នុងឋានៈជាម្ចាស់ទឹកដីពិតប្រាកដ និងសូមឱ្យទទួលបាននូវពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមឈាមទាំអស់ ព្រះមេត្តា និងមេត្តាទទួលនូវការគោរព និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំព្រះករុណាខ្ញុំ ៕ សូមអរព្រះគុណ និងអរគុណ ។

*រាជធានីភ្នំពេញ ថ្ងៃព្រហស្បតិ៍ ០១កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១១ ខែមេសា ព.ស.២៥៥៦ គ.ស.២០១៣*

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**

សមាជិកព្រឹទ្ធសភា

Website: www.khmerkromngo.org
Temporary Headquarters: House # 10B, Street 234, Tuk Laak commune, Tuol Kork district, Phnom Penh, Kingdom of Cambodia
Telephones: 012 908 882, 090 477 007; E-mails: thachsetha@gmail.com, kkcpressoffice@yahoo.com